វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១៣ លេខ ០២

## លុបបំបាត់ឧបសគ្គរាំងស្ទះដល់ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា[១]

“ការផ្សារភ្ជាប់ទំនាក់ទំនងរវាងអង្គការកសិករ និងគម្រោងកសិកម្មតាមកិច្ចសន្យា អាចជួយបង្កើនអំណាចចរចា និងអត្ថប្រយោជន៍សម្រាប់កសិករក្រីក្រ និងធានាឲ្យផលិតផលនាំចេញមានស្ថិរភាពល្អទាំងបរិមាណ និងគុណភាព។”

*បណ្ឌិត ថេង វុទ្ធី, អ្នកសម្របសម្រួល*
*កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI*

### កសិកម្មសម្រាប់គ្រប់គ្នា និងការអភិវឌ្ឍប្រកបដោយចីរភាព

ភាពសម្បូរដីកសិកម្មមានជីជាតិ ព្រៃឈើ និងមច្ឆាជាតិ បង្ហាញនូវឧត្តមភាពប្រៀបធៀបជាសក្តានុពលរបស់កម្ពុជា ដែលអាចជំរុញដល់ការអភិវឌ្ឍប្រកបដោយចីរភាពភាពសម្រាប់គ្រប់គ្នា ប្រសិនបើមានការគ្រប់គ្រងធនធានទាំងនោះប្រកបដោយទំនួលខុសត្រូវ។

អនុវិស័យសំខាន់ៗ (ស្រូវ ដំណាំផ្សេងទៀត សត្វចិញ្ចឹម ជលផល និងព្រៃឈើ) ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើននៅកម្ពុជា ដោយផ្តល់ការងារឲ្យប្រមាណ ៧២% នៃកម្លាំងពលកម្មសរុប ក្នុងនេះមានទាំងប្រជាជនក្រីក្រមួយភាគធំផង។ វិស័យកសិកម្ម ជាពិសេសដំណាំស្រូវ ជាវិស័យសំខាន់បំផុតមួយសម្រាប់ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រ។

ភាពធន់នៃវិស័យកសិកម្ម ជំរុញឡើងដោយការវិនិយោគរយៈពេលវែងរបស់កសិករមានដីតូចៗ ជាសមាសធាតុដ៏ចាំបាច់មួយនៃកំណើនម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថិរភាព។ ចំណុចនេះស្តែងឡើងយ៉ាងច្បាស់ក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុសកល៖ វិស័យកាត់ដេរ សំណង់ និងទេសចរណ៍ បានរួមចុះ ដោយសារការដកចេញវិញនូវមូលធនបរទេស ប៉ុន្តែវិស័យកសិកម្មនៅតែមានកំណើនរឹងមាំរហូតដល់ ៤ ទៅ ៥%។ អត្រាកំណើននេះ បានជួយរក្សាសន្ទុះសេដ្ឋកិច្ចកម្ពុជាក្នុងអំឡុងពេលមានការប៉ះទង្គិចធ្ងន់ធ្ងរមិនធ្លាប់មានពីមុន ជួយឲ្យកម្ពុជាចៀសផុតពីអត្រាកំណើនអវិជ្ជមាន និងដើរតួជាសំណាញ់សុវត្ថិភាពសង្គមថ្នាក់ជាតិសម្រាប់ប្រជាជនកម្ពុជាមួយភាគធំ រាប់បញ្ចូលទាំងប្រជាជនក្រីក្រនៅទីក្រុងផង។

សម្រាប់សន្តិសុខស្បៀង គេត្រូវពិនិត្យពីការអភិវឌ្ឍកសិកម្មក្នុងបរិបទសាកលនៃ កំណើនតម្រូវការអាហារមនុស្ស និងចំណីសត្វ ដោយសារកំណើនប្រជាជន ការអភិវឌ្ឍសង្គម និងការផ្លាស់ប្តូរក្នុងលំនាំនៃការប្រើប្រាស់។ នៅកម្ពុជា វិស័យកសិកម្មផ្តល់ស្បៀងអាហារដល់ប្រជាជនជិត ១៥លាននាក់ ដែលកំពុងកើនឡើង និងកើនចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់។ ដូចនេះ ការធានានិងរក្សាឲ្យការផ្គត់ផ្គង់ស្បៀងអាហារមានស្ថិរភាព សំខាន់ខ្លាំងណាស់សម្រាប់សន្តិសុខស្បៀងនៅកម្ពុជាទៅអនាគត។

អ្នកបង្កើតគោលនយោបាយបានទទួលស្គាល់ថា វិស័យកសិកម្មសំខាន់ណាស់ចំពោះការអភិវឌ្ឍមានចីរភាព និងសម្រាប់គ្រប់គ្នានៅកម្ពុជា ដោយក្នុងប្រាំឆ្នាំចុងក្រោយនេះ មានគោលនយោបាយផ្សេងៗនៅកម្រិតជាតិ និងកម្រិតតាមវិស័យ បានជួយបង្កើនប្រសិទ្ធភាពក្នុងវិស័យនេះ។ តួយ៉ាង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ (២០០៨) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៩-១៣) បានដាក់ចេញនូវកម្មវិធីកំណែទម្រង់មានមហិច្ឆតាខ្ពស់និងរចនារៀបចំឡើងដើម្បី បង្កើនផលិតភាពនិងទិន្នផល ធ្វើពិពិធកម្មលើវិស័យកសិកម្ម និងសម្រេចឲ្យបាននូវកំណើនប្រកបដោយចីរភាពសម្រាប់គ្រប់គ្នា។

យុទ្ធសាស្ត្រផ្នែកគោលនយោបាយ បានដាក់បញ្ចូលនូវ កំណែទម្រង់ស៊ីជម្រៅនៃក្របខ័ណ្ឌស្ថាប័នសម្រាប់អភិបាលកិច្ចដី ព្រៃឈើ និងជលផល។ ឯកសារគោលនយោបាយស្តីពីការនាំចេញអង្ករ មានគោលបំណងទាញយកអត្ថប្រយោជន៍ពីសក្តានុពលនៃ "មាសស" របស់កម្ពុជា ដោយជំរុញគុណភាពអង្ករឲ្យបានស្របតាមស្តង់ដារអន្តរជាតិ ជំរុញឲ្យការកិនស្រូវមានលក្ខណៈប្រសើរឡើងដើម្បីបង្កើនតម្លៃបន្ថែម និងជំរុញលក្ខខណ្ឌអំណោយផលផ្នែកពាណិជ្ជកម្ម ដើម្បីទាក់ទាញវិនិយោគពីវិស័យឯកជន។

[១] អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញក្នុងវគ្គទី៣ នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣ បកស្រាយដោយ បណ្ឌិត ម៉ាក់ សឿន ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, បណ្ឌិត ថេង វុទ្ធី អ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI និង លោក Daniel Mitchell នាយកប្រតិបត្តិនៃក្រុមហ៊ុន SRP International Group។

* លទ្ធផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៣
ក្នុងកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

រូបភាព ១៖ ផ្ទៃដីដាំដុះ គិតតាមមុខដំណាំ ឆ្នាំ២០១១ (ជាភាគរយ)




ប្រភព៖ បណ្ឌិត ថេង វុទ្ធី សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា

មានក្របខ័ណ្ឌគោលនយោបាយជាច្រើន ដែលសំដៅដោះស្រាយដោយផ្ទាល់នូវឧបសគ្គផ្សេងៗចំពោះគ្រួសារក្រីក្រនៅជនបទ។ តួយ៉ាង យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ឆ្នាំ២០១២-១៣ ព្យាយាមបង្កើនសន្តិសុខស្បៀងនិងចំណូល កសាងភាពធន់នៃគ្រួសារនៅជនបទទៅនឹងវិបត្តិសេដ្ឋកិច្ច និងលើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងដីឲ្យមានចីរភាព ដោយផ្អែកលើសហគមន៍។

យន្តការស្ថាប័នថ្នាក់តំបន់មួយចំនួនបានដាក់អនុវត្តហើយ ដើម្បីរក្សាការផ្គត់ផ្គង់ស្បៀងក្នុងអំឡុងពេលមានវិបត្តិ តួយ៉ាងដូចជា ក្របខ័ណ្ឌសន្តិសុខស្បៀងរួមគ្នារបស់អាស៊ាន (AIFS) ដែលសម្រាប់ជួយទ្រទ្រង់ដល់សន្តិសុខស្បៀងរយៈពេលវែងរបស់ប្រទេសជាសមាជិក។ ក្របខ័ណ្ឌ AIFS នេះ មានសមាសភាគចម្បង ៤ គឺ៖ ជំនួយសង្គ្រោះបន្ទាន់/ក្នុងពេលខ្វះខាត ការអភិវឌ្ឍពាណិជ្ជកម្មស្បៀងប្រកបដោយចីរភាព ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងរួម និង ការអនុវត្តបែបថ្មីផ្នែកកសិកម្ម។

ការផ្លាស់ប្ដូរលើបទបញ្ញត្តិផ្សេងៗ បានរួមចំណែកជួយកែប្រែទម្រង់វិស័យកសិកម្មនៅកម្ពុជាក្នុងពេលមួយទសវត្សរ៍កន្លងទៅ។ ផលិតកម្មស្រូវ បានកើនឡើងមួយជាពីរក្នុងអំឡុងពេលនោះ ដោយមានអតិរេកស្រូវដល់ប្រមាណ ៤,៣លានតោន ក្នុងឆ្នាំ២០១១។ ដំឡូងឈើ ពោត និងសណ្ដែកសៀង បានរីកលូតលាស់ យ៉ាងលឿនសម្រាប់ការនាំចេញ ហើយក្នុងពេលបច្ចុប្បន្នបានរួមចំណែកមួយភាគធំ ក្នុងសកម្មភាពកសិកម្ម (រូបភាព ១)។ ផលិតកម្មសត្វចិញ្ចឹម ក៏កើនឡើងដែរ ដោយចំនួនសត្វមាន់ទាសរុបចិញ្ចឹមក្នុងស្រុក បានកើនពី ១៦លានក្បាល នៅឆ្នាំ២០០៧ ដល់ជាង ២៣លានក្បាល នៅឆ្នាំ២០១២។

កំណើនសេដ្ឋកិច្ច បានជួយកាត់បន្ថយភាពក្រីក្រយ៉ាងច្រើនគួរឲ្យចាប់អារម្មណ៍៖ អត្រាជនក្រីក្រនៅតាមជនបទ បានធ្លាក់ចុះពី ៣៩% នៅឆ្នាំ១៩៩៤ មកត្រឹម ៣០,១% នៅឆ្នាំ២០០៧ ទោះបីមិនទាន់អាចរកបានទិន្នន័យផ្លូវការសម្រាប់ប៉ុន្មានឆ្នាំថ្មីៗនេះក្ដី។

ទោះមានជោគជ័យដូច្នេះក្ដី ក៏វិស័យកសិកម្មនៅកម្ពុជា ជាពិសេសផលិតកម្មស្រូវ មិនទាន់អាចប្រើអស់ សក្ដានុពលទេ ទាំងនៅក្នុងទិន្នផលស្រូវ និងការឈានឡើងក្នុងខ្សែចង្វាក់តម្លៃបន្ថែម។ ដើម្បីសម្រេចគោលដៅថ្នាក់ជាតិក្លាយជាអ្នកនាំចេញស្រូវធំជាងគេ លំដាប់ទី៣ លើពិភពលោកនៅឆ្នាំ២០១៥ ត្រូវមានការរីកលូតលាស់ក្នុងទិដ្ឋភាពជាច្រើននៃផលិតកម្ម។

ក្នុងបញ្ហាសមធម៌វិញ មានការបារម្ភថា កំណើនមិនបានផ្ដល់ផលប្រយោជន៍ដល់អ្នកក្រីក្រខ្លាំងនោះទេ។ ការសិក្សានៅតំបន់បឹងទន្លេសាបកាលពីពេលថ្មីៗ រកឃើញថា អត្រាស្គមស្គាំងក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ កើនឡើងពី ១០% នៅឆ្នាំ២០១០ ដល់ ១៤,៦% នៅឆ្នាំ២០១២។ អង្គការសុខភាពពិភពលោក បានចាត់ថ្នាក់កុមារទាំងនេះចូលក្នុង ក្រុមខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ ជាលទ្ធផលនៃកង្វះអាហារូបត្ថម្ភ មានកុមារអាយុក្រោម៥ឆ្នាំ ៤០% កើតជម្ងឺក្រិន និង ២៩% ខ្វះទម្ងន់។ តួលេខបែបនេះគួរឲ្យបារម្ភខ្លាំងណាស់ និងផ្ដល់គំនិតថា អ្នកបង្កើតគោលនយោបាយត្រូវព្យាយាមច្រើនថែមទៀត ដើម្បីផ្ដោតឲ្យចំអ្នកក្រីក្រខ្លាំង អ្នកគ្មានដីធ្លី និងកសិករតូចតាច។

## ឧបសគ្គចំពោះការបង្កើនផលិតកម្មកសិកម្ម

ការស្រាវជ្រាវនាពេលថ្មីៗនេះ បង្ហាញថា ផលិតកម្មកសិកម្មត្រូវរាំងស្ទះដោយសារបញ្ហាធាតុចូលកសិកម្មមានតម្លៃខ្ពស់ពេក និងគ្មានការត្រួតពិនិត្យត្រឹមត្រូវ។ ករណីសិក្សាមួយបានរកឃើញថា បទបញ្ញត្តិមិនមានប្រសិទ្ធភាពបានកាត់បន្ថយរបាំងលើការនាំចូល ដែលនាំឲ្យមានការលក់ចែកចាយជីមានគុណភាពទាប៖ ជាក់ស្ដែងប្រហែល ១០% នៃជីនៅក្នុងតំបន់សិក្សា គឺជាផលិតផលក្លែងក្លាយ។ ការប្រើធាតុចូលក្លែងក្លាយ ឬមានការលាយបន្លំ អាចកាត់បន្ថយទិន្នផលដំណាំរហូតដល់ប្រហែល ២៨៥-៣៥០ដុល្លារ ក្នុងមួយកសិដ្ឋានក្នុងមួយឆ្នាំ ហើយវាប៉ះទង្គិចធ្ងន់បំផុតទៅលើជនក្រីក្រខ្លាំង។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានប្រឹងប្រែងផ្សព្វផ្សាយនូវពូជស្រូវមានទិន្នផលខ្ពស់ក្នុងទូទាំងប្រទេស។ ប៉ុន្តែការបញ្ចុះបញ្ចូលកសិករឲ្យប្រើពូជស្រូវទាំងនេះជាការលំបាក ព្រោះពួកគាត់តែងជ្រើសប្រើប្រាស់ពូជស្រូវមានទីផ្សារស្រាប់ ដូចជា ពូជស្រូវ IR 504 មកពីវៀតណាម ជាដើម។ ម្យ៉ាងទៀត កសិករក៏លំបាកនឹងរកបានគ្រាប់ពូជទាំងនេះដែរ ដោយសារការផ្គត់ផ្គង់នៅខ្វះ និងថ្លៃដ៏ខ្ពស់។ ការសិក្សានាពេលថ្មីៗមួយ រកឃើញថា ការផ្គត់ផ្គង់គ្រាប់ពូជមានត្រឹម ២០% នៃតម្រូវការប៉ុណ្ណោះ។ គោលនយោបាយទៅថ្ងៃអនាគត ត្រូវផ្ដោតលើការលុបបំបាត់ឧបសគ្គរាំងស្ទះការផ្គត់ផ្គង់គ្រាប់ពូជ។

ឥណទានស្ថិតក្នុងចំណោម ធាតុចូលដ៏ថ្លៃៗបំផុតនៃការដាំដុះ ជាពិសេសសម្រាប់កសិករមានដីតូចៗ ដែលពឹងផ្អែកលើទីផ្សារឥណទានក្រៅផ្លូវការ។ កសិករភាគច្រើន ទទួលយកកម្ចីមានការប្រាក់ខ្ពស់ (ប្រហែល ៥% ក្នុងមួយខែ) ពីអ្នកផ្ដល់កម្ចីក្រៅផ្លូវការ ព្រោះពួកគាត់អាចរកវាបានយ៉ាងឆាប់ទាន់ពេលត្រូវការ។ ចំពោះសកម្មភាព MFI វិញ ទោះបីវាកើនឡើងក្ដី ក៏អត្រាការប្រាក់នៅតែមានកម្រិតខ្ពស់ដល់ប្រហែល ២,៥% ក្នុងមួយខែ ដែលជាបន្ទុកដ៏ធ្ងន់សម្រាប់កសិករមានដីតូចៗ។

ឥណទាន ជី ថ្នាំសម្លាប់សត្វចង្រៃ និងប្រេងឥន្ធនៈ មានថ្លៃខ្ពស់ គួបផ្សំនឹង កង្វះសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បានធ្វើឲ្យការដាំដំណាំជាច្រើនមិនមានប្រសិទ្ធភាពល្អ។ ការធ្វើកសិកម្មតាមរបៀបថ្មី បាននិងកំពុងរីកលូតលាស់ ប៉ុន្តែមិនទាន់បានពង្រីកទៅដល់ប្រជាជនក្នុងទូទាំងប្រទេសទេ។ កម្ពុជាចាំបាច់ត្រូវកែលំអ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បើសិនចង់ធ្វើឲ្យអនុវិស័យកសិកម្មនានាមានលក្ខណៈជំនួញ និងចង់ឲ្យវិស័យកសិកម្មទាំងមូលកាន់តែមានប្រសិទ្ធភាព និងមានពិពិធកម្មខ្លាំង។ ឧទាហរណ៍ នៅក្នុងផលិតកម្មស្រូវ កសិករត្រូវតែទទួលបានការបណ្ដុះបណ្ដាលពីវិធីគ្រប់គ្រងសត្វចង្រៃ ការប្រើប្រាស់ជី និងបច្ចេកទេសដាំដុះបែបទំនើបផ្សេងៗ។ ក្នុងកម្មវិធីការចិញ្ចឹមសត្វ គួរបង្កើតគោលនយោបាយជំរុញការចិញ្ចឹមសត្វ កម្មវិធីបង្កាត់ពូជ និងសេវាផ្សព្វផ្សាយបច្ចេកទេសបសុពេទ្យ។

ការនាំយកទំនិញទៅកាន់ទីផ្សារ ត្រូវចំណាយប្រាក់ច្រើន ដោយសារហេដ្ឋារចនាសម្ព័ន្ធនៅអន់ខ្សោយ ដែលកាត់បន្ថយប្រាក់ចំណេញរបស់ផលិតករ និងបង្កឧបសគ្គដល់ការវិនិយោគផ្នែកកសិកម្ម។ ការជំរុញច្រករបៀងសេដ្ឋកិច្ចក្នុងតំបន់ អនុវត្តដោយធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបានជោគជ័យក្នុងការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់ ដែលជាប់ពាក់ព័ន្ធនឹងការនាំចេញផលិតផលកសិកម្ម។ ទោះបីការដឹកជញ្ជូនរវាងទីក្រុងបានល្អឡើងច្រើនក្តី ក៏បណ្តាញផ្លូវជនបទមានគុណភាពអន់ នៅតែជាមូលហេតុសំខាន់មួយនៃតម្លៃដឹកជញ្ជូនខ្ពស់ ហើយជាក់ស្តែងវាបានកាត់ផ្តាច់កសិករពីទីផ្សារនានា។

ចំណុចខ្វះខាតដ៏សំខាន់មួយនៅក្នុងទីផ្សារផលិតផលកសិកម្ម គឺការចែកចាយព័ត៌មានទីផ្សារមិនស្មើភាព ដែលបណ្តាលមកពីពាណិជ្ជកម្មក្រៅផ្លូវការដែលមានច្រើនពាសពេញ។ ដោយសារមិនមានប្រភពផ្លូវការអ្វីមួយនៃព័ត៌មានទីផ្សារ និងក្របខ័ណ្ឌធ្វើពាណិជ្ជកម្ម ពួកឈ្មួញកណ្តាល អាចទាញយកចំណេញពីបញ្ហាទទួលបានព័ត៌មានមិនដូចគ្នាដោយធ្វើការកំណត់ថ្លៃ និងលក្ខខណ្ឌជួញដូរផ្សេងៗក្នុងលក្ខណៈមិនផ្លូវការ ធ្វើឲ្យខាតបង់ដល់ផលិតករ។ រចនាសម្ព័ន្ធទីផ្សារមិនផ្លូវការនេះក៏ងាយរងគ្រោះដោយការឡើងចុះថ្លៃតាមទំនើងចិត្ត និងការប្រែប្រួលក្នុងតម្រូវការដែរ ដែលបង្កើតនូវអស្ថិរភាពកាន់តែច្រើនចំពោះផលិតករ។ អ្នកដែលខាតបង់ច្រើនជាងគេក្នុងការដោះដូរបែបនេះ គឺកសិករតូចតាចដែលផលិតស្រូវ។

កង្វះព័ត៌មានទីផ្សារ ក៏បង្កើនបន្ទុកចំណាយលើការជួញដូរ សម្រាប់ភាគីអ្នកមានតម្រូវការដែរ។ រចនាសម្ព័ន្ធមិនផ្លូវការនៃខ្សែចង្វាក់កំណត់តម្លៃ បានធ្វើឲ្យក្រុមហ៊ុនកិនស្រូវពិបាកនឹងទទួលបានការផ្គត់ផ្គង់មានស្ថិរភាពល្អ ហើយគុណភាពផលិតផលក៏ប្រែប្រួលដែរ។ កង្វះស្តង់ដារគុណភាព និងការមិនផ្សារភ្ជាប់គ្នារវាងគុណភាព និងថ្លៃ វាបង្កើតនូវភាពមិនប្រាកដប្រជា ផ្តល់ឱកាសសម្រាប់ការស្វែងរកកម្រៃក្រៅផ្លូវការ និងធ្វើឲ្យដំណើរការទីផ្សារគ្មានប្រសិទ្ធភាព។ យន្តការជាផ្លូវការនិងមានតម្លាភាព ដែលផ្សារភ្ជាប់គុណភាព ទៅនឹងថ្លៃ ដូចជា បទបញ្ញត្តិលើការគ្រប់គ្រងគុណភាព ជាដើម សំខាន់ខ្លាំងណាស់ក្នុងការជួយឲ្យទីផ្សារមានដំណើរការប្រកបដោយប្រសិទ្ធភាព។

ក្របខ័ណ្ឌគ្រប់គ្រងដីធ្លីដ៏មានប្រសិទ្ធភាពនានា ជាផ្នែកមួយសំខាន់បំផុតនៃសេដ្ឋកិច្ចបែបកសិកម្ម ព្រោះវាជួយជំរុញវិនិយោគតាមរយៈការធានាសិទ្ធិកាន់កាប់ដីធ្លី ជួយឲ្យទីផ្សារអាចបែងចែកដីធ្លីប្រកបដោយប្រសិទ្ធភាព និងជួយឲ្យរដ្ឋាភិបាលអាចរក្សាតុល្យភាពរវាងមុខព្រួញផ្សេងៗនៃសេដ្ឋកិច្ចបែបកសិកម្ម។ អាទិភាពខាងគោលនយោបាយ គឺការរក្សាតុល្យភាពរវាងតម្រូវការរបស់កសិករតូចតាច និងវិនិយោគផ្ទាល់ពីបរទេស (FDI) ទ្រង់ទ្រាយធំទៅក្នុងកសិឧស្សាហកម្ម។ បើសិនមានគោលនយោបាយល្អសមរម្យ ក្របខ័ណ្ឌទាំងនេះអាចជួយបំពេញឲ្យគ្នាទៅវិញទៅមក។

ការបែងចែកដីកសិកម្មមិនមានសមធម៌នៅកម្ពុជា ជះឥទ្ធិពលអវិជ្ជមាន ទាំងទៅលើប្រសិទ្ធភាពផលិតកម្ម និងលើសមធម៌នៅចំពោះមុខភាពក្រីក្រ។ រូបភាព ២ បង្ហាញថា ក្នុងទសវត្សរ៍កន្លងទៅនេះ គ្រួសារនៅជនបទដែលគ្មានដីធ្លី មានពី ១៥% ទៅ ២០% ហើយអ្នកមានដីតិចជាងមួយហិកតា មានប្រហែល ៤០%។ ក្នុងករណីជាច្រើន ពួកគាត់មានលទ្ធភាពត្រឹមការធ្វើកសិកម្មចិញ្ចឹមពោះប៉ុណ្ណោះ ព្រោះបញ្ហាកង្វះទ្រព្យធន មិនអាចឲ្យពួកគាត់បង្កើតនូវអតិរេកផលដំណាំដែលរួមចំណែកនាំឲ្យមានការរីកលូតលាស់នោះទេ។

សម្បទានដីសេដ្ឋកិច្ច (ELCs) ដែលជារឿយៗជាប់ពាក់ព័ន្ធនឹងការរឹបអូសដីពីកសិករតូចតាច ជាកត្តាមួយរួមចំណែកបង្កើតនូវវិសមភាពដីធ្លី។ ក្នុងករណីជាច្រើន ដីដែលបានដកហូតនោះ មិនបានយកទៅប្រើប្រាស់ប្រកបដោយផលិតភាពឡើយ។ ដីនោះត្រូវតែធ្វើការបែងចែកឡើងវិញទៅឲ្យអ្នកគ្មានដីធ្លី និងកសិករតូចតាច ដែលអាចប្រើប្រាស់វាបានល្អប្រសើរ ដើម្បីបង្កើតជាដើមទុនសម្រាប់ពួកគាត់។

ការគ្រប់គ្រងធនធានជលផល និងព្រៃឈើឲ្យមានចីរភាព ក៏កំពុងជួបបញ្ហាមួយចំនួនដែរ។ ជលផលជាអនុវិស័យជំរុញកំណើនសំខាន់មួយ ប៉ុន្តែត្រូវធ្វើកំណែទម្រង់ក្នុងការបែងចែកឡូត៍នេសាទ និងការត្រួតពិនិត្យឲ្យការនេសាទមានលក្ខណៈស្របច្បាប់ ដើម្បីថែរក្សាស្តុកត្រី និងជីវៈចម្រុះឲ្យនៅគង់វង្ស។ គួរធ្វើការស្រាវជ្រាវច្រើនថែមទៀតអំពីស្តុកត្រីដើម្បីជួយឲ្យការបែងចែកឡូត៍នេសាទអនុវត្តបានត្រឹមត្រូវ។ ម្យ៉ាងទៀត ត្រូវបង្កើនកិច្ចប្រឹងប្រែងក្នុងការចាត់ថ្នាក់និងកំណត់ព្រំដែនព្រៃឈើ និងការ

រូបភាព ២៖ ការបែងចែកដីនៅកម្ពុជា




ប្រភព៖ បណ្ឌិត ចេង វុទ្ធី សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា

ពិនិត្យតាមដានលើការប្រើប្រាស់ធនធានព្រៃឈើ។ ការអភិរក្សជីវៈចម្រុះសំខាន់ខ្លាំងណាស់ទាំងចំពោះចីរភាពបរិស្ថាន និងចីរភាពនៃការប្រើប្រាស់ព្រៃឈើជាធនធានសេដ្ឋកិច្ច។

## ការកសាងលើគោលនយោបាយមានស្រាប់

កម្ពុជា បានកសាងល្អហើយនូវ ក្របខ័ណ្ឌគោលនយោបាយសម្រាប់លើកកម្ពស់ប្រសិទ្ធភាពវិស័យកសិកម្ម។ ដូច្នេះសម្រាប់ពេលបច្ចុប្បន្ន គួរផ្តោតការយកចិត្តទុកដាក់លើ ការវាយតម្លៃពីដំណើរការគោលនយោបាយទាំងនេះ ការកែលំអបន្ថែមផ្សេងៗលើគោលនយោបាយ និង ការពង្រឹងបណ្តាស្ថាប័នអនុវត្ត។ ចំណុចស្នូលក្នុងការងារនេះ គឺការស្រាវជ្រាវគ្រប់ជ្រុងជ្រោយពីផលប៉ះពាល់នៃគោលនយោបាយ និងការផ្សារភ្ជាប់ការស្រាវជ្រាវទៅនឹងការបង្កើតគោលនយោបាយ។

ការស្រាវជ្រាវបង្ហាញថា ការជំរុញការធ្វើកសិកម្មតាមកិច្ចសន្យានៅកម្ពុជា បានដោះស្រាយនូវឧបសគ្គជាច្រើនដែលមានលើកឡើងក្នុងអត្ថបទសង្ខេបនេះ។ កសិករជាប់កិច្ចសន្យា ទទួលបានគ្រាប់ពូជមានគុណភាពល្អជាងមុន និងអាចរៀនសូត្របច្ចេកទេសកសិកម្មទំនើបៗ មានលទ្ធភាពទទួលបានឥណទានមានការប្រាក់ទាប និងអាចធ្វើការដោះដូរនៅក្នុងក្របខ័ណ្ឌស្ថាប័ននានា ដែលផ្តល់នូវកម្រិតថ្លៃមានសមធម៌ និងតម្រូវការកាន់តែមានស្ថិរភាព។ ប៉ុន្តែ ការធ្វើកសិកម្មតាមកិច្ចសន្យា នៅមានបញ្ហាចោទជាច្រើន។ អ្នកផ្តល់កិច្ចសន្យាត្រួតត្រាលើដំណើរការផលិតកម្ម ហើយកសិករមានអំណាចតិចតួចណាស់ក្នុងការចរចា មិនអាចមានឥទ្ធិពលអ្វីទៅលើលក្ខខណ្ឌកិច្ចសន្យាទេ គឺគ្រាន់តែអាចឯកភាព ឬមិនឯកភាពតាមលក្ខខណ្ឌក្នុងកិច្ចសន្យាប៉ុណ្ណោះ។ កសិករខ្លះយល់ថា កិច្ចព្រមព្រៀងនោះមានលក្ខណៈស្មុគស្មាញខ្លាំងណាស់។ កសិករជាច្រើនបានដកខ្លួនចេញពីគម្រោងចុះកិច្ចសន្យានានា ដោយសារតែកត្តាទាំងឡាយដូចខាងលើ។ ដូច្នេះ គោលនយោបាយទៅអនាគត គួរផ្តោតលើការតម្រឹមកិច្ចព្រមព្រៀងតាមកិច្ចសន្យា ដើម្បីឲ្យកសិករមានសិទ្ធិបញ្ចេញមតិច្រើនថែមទៀត ក្នុងការតាក់តែងកិច្ចសន្យា។

អង្គការកសិករ ជាយន្តការស្ថាប័នមួយដែលកំពុងរីកលូតលាស់សម្រាប់ផ្តល់សិទ្ធិអំណាចដល់កសិករ។ នាបច្ចុប្បន្ននៅទូទាំងប្រទេសមានដល់ ១៤.០០០ ផលិតករ និងក្រុមអ្នកប្រើប្រាស់ធនធាន ក្នុងនេះមានទាំង ២៤០ សហករណ៍កសិកម្មផង។ អង្គការទាំងនេះធ្វើការជំរុញផលិតភាពកសិកម្ម ដោយជួយឲ្យកសិករមានលទ្ធភាពកាន់តែប្រសើរក្នុងការចរចាថ្លៃសម្រាប់ផលិតផលរបស់ខ្លួន និងដោយជួយផ្សព្វផ្សាយនូវព័ត៌មាន និងបច្ចេកទេសកសិកម្ម។ ទោះយ៉ាងនេះក្តី CDRI បានរាយការណ៍ថា កសិករតូចតាច ជារឿយៗមិនឃើញមានអត្ថប្រយោជន៍អ្វីពីការចូលរួមក្នុងអង្គការកសិករនោះទេ។ ដោយផ្តោតការងារទៅលើឥណទាន និងបច្ចេកទេសកសិកម្ម អង្គការកសិករមិនបានដោះស្រាយបញ្ហាគ្រឹះនៃលទ្ធភាពរបស់កសិករតូចតាចក្នុងការប្រើប្រាស់ធាតុចូល និងចូលទៅក្នុងទីផ្សារលក់ផលិតផលឡើយ។ ដូច្នេះត្រូវមានវិធីសាស្ត្រដោះស្រាយកាន់តែទាំងមូលឡើង ដើម្បីតភ្ជាប់អង្គការកសិករទៅនឹងការធ្វើកសិកម្មតាមកិច្ចសន្យា និងដើម្បីដោះស្រាយឧបសគ្គជាច្រើនដែលរារាំងវិនិយោគរបស់កសិករតូចតាច។

សម្បទានដីសេដ្ឋកិច្ច (ELCs) និង សម្បទានដីសង្គមកិច្ច (SLCs) ជាឧបករណ៍ដ៏ខ្លាំងក្លាដែលរដ្ឋាភិបាល អាចប្រើប្រាស់ដើម្បីបង្កើនប្រសិទ្ធភាព និងសមធម៌នៃការបែងចែកដីកសិកម្ម។

សម្បទានដីសេដ្ឋកិច្ច សំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍកសិឧស្សាហកម្មក៏ពិតមែន ប៉ុន្តែជារឿយៗវាមានផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសង្គម។ ដូច្នេះ ត្រូវមានការត្រួតពិនិត្យ និងការរចនារៀបចំកាន់តែល្អ ដើម្បីទាក់ទាញមូលធនប្រកបដោយទំនួលខុសត្រូវខ្ពស់ ដូចជា FDI របស់ស្ថាប័នផ្សេងៗ (គម្រោងប្រាក់សោធននិវត្តន៍របស់ក្រុមហ៊ុន, មូលនិធិវិនិយោគ, ប្រាក់ផ្តល់ឲ្យសាកលវិទ្យាល័យ) ដែលតែងមានរបៀបវារៈផ្នែកបរិស្ថាន និងសង្គម។ វិនិយោគិនប្រកបដោយការទទួលខុសត្រូវ តែងបង់ពន្ធ គោរពច្បាប់ការងារ ធ្វើការត្រួតពិនិត្យតាមដានលក្ខខណ្ឌការងារ ទោះបីមាន ឬគ្មានលក្ខណៈវិនិច្ឆ័យរបស់រដ្ឋាភិបាលក្តី ប្រើប្រាស់ដីមានគុណភាពល្អក្នុងលក្ខណៈគិតគូរដល់បរិស្ថាន ហើយអនុវត្តការងារស្របតាមស្តង់ដារពិភពលោក និងស្របតាមនីតិវិធីរបស់ក្រុមហ៊ុនល្អ។

ចំពោះសម្បទានដីសេដ្ឋកិច្ចដែលមានរបៀបរបបការងារមិនល្អ គឺត្រូវតែស្រាវជ្រាវឲ្យឃើញ និងធ្វើការបែងចែកដីឡើងវិញ។ វិនិយោគិនដែលពាក់ព័ន្ធនឹងទង្វើប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន តាមពិតគេធ្វើឲ្យកម្ពុជាក្លាយជាកន្លែងមួយលំបាកដល់ វិនិយោគិនប្រកបដោយការទទួលខុសត្រូវខ្ពស់ចូលមកធ្វើការបណ្តាក់ទុន។ ដីធ្លីដែលប្រើប្រាស់មិនបានត្រឹមត្រូវតាមបទបញ្ញត្តិ ត្រូវតែធ្វើការបែងចែកឡើងវិញទៅឲ្យអ្នកគ្មានដីធ្លី។ វិធីនេះវាជួយបង្កើនប្រសិទ្ធភាព និងកាត់បន្ថយភាពក្រីក្រ។ ការបែងចែកដីឡើងវិញកំពុងមានអនុវត្តហើយនាបច្ចុប្បន្ន ប៉ុន្តែក្នុងល្បឿនយឺតៗ។ តួយ៉ាង សម្បទានដីសេដ្ឋកិច្ចមានផ្ទៃដីប្រមាណ ១៣៣.០០០ ហិកតា ត្រូវបានលុបចោល តាំងពីសម្តេចនាយករដ្ឋមន្ត្រីបានប្រកាសពីនីតិវិធីត្រួតពិនិត្យឡើងវិញឲ្យបានកាន់តែតឹងរ៉ឹង ប៉ុន្តែក្នុងនេះ មានផ្ទៃដីតែ ៤០.០០០ ទៅ ៥០.០០០ហិកតាប៉ុណ្ណោះ ដែលបានបម្រុងទុកសម្រាប់ការបែងចែកឡើងវិញក្នុងលក្ខណៈជាសម្បទានដីសង្គមកិច្ច។

កម្មវិធីចុះបញ្ជីដីធ្លីថ្នាក់ជាតិរបស់រដ្ឋាភិបាល ក៏បាននិងកំពុងបង្កើនល្បឿននៅទីជនបទដែរ។ ការចែកចាយប័ណ្ណកម្មសិទ្ធិដីប្រកបដោយតម្លាភាព គណនេយ្យភាព និងសមធម៌ សំខាន់ខ្លាំងណាស់ ដើម្បីធានាសន្តិសុខក្នុងការកាន់កាប់ដី ជាពិសេសចំពោះកសិករតូចតាចដែលងាយរងគ្រោះដោយការរឹបអូសយកដី។ វិធានការនេះ ជាមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់ការបង្កើនវិនិយោគរបស់កសិករតូចតាច និងប្រសិទ្ធភាពទីផ្សារដីធ្លី។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ (៨៥៥ ២៣) ៨៨០ ៧៣៤

e-mail: cdri@cdri.org.kh, website: www.cdri.org.kh